ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៦០ សហវ-ប្រក

ប្រកាស

ស្តីពី

ការបង្កើតក្រុមការងារស្តីពីការយកពន្ធលើផលិតផលថ្នាំជក់
និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមអនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ឆ្នាំ២០០៣
- យោងតាមពិធីសារស្តីពីការលុបបំបាត់ការធ្វើពាណិជ្ជកម្មខុសច្បាប់នូវផលិតផលថ្នាំជក់
- យោងតាមសំណើរបស់ក្រសួងសុខាភិបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារស្តីពីការយកពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់ ដើម្បីសិក្សា និងរៀបចំក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការអនុវត្តមាត្រា៦ ដែលចែងអំពីការដំឡើងតម្លៃនិងពន្ធលើផលិតផលថ្នាំជក់ ដើម្បីកាត់បន្ថយតម្រូវការប្រើប្រាស់ផលិតផលថ្នាំជក់ និងមាត្រា ១៥ ដែលចែងអំពីមធ្យោបាយបង្ក្រាបការធ្វើពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់ នៃអនុសញ្ញារបស់អង្គការសុខភាពពិភពលោកស្តីពីការត្រួតពិនិត្យថ្នាំជក់ឆ្នាំ២០០៣ និងពិធីសារស្តីពីការលុបបំបាត់ពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់ ។

**ប្រការ២.-**

ក្រុមការងារស្តីពីការយកពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់ មានសមាជិកដូចខាងក្រោម÷

| | |
|---|---|
| ១-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២-តំណាងក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៤-តំណាងអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៥-តំណាងនាយកដ្ឋានរដ្ឋាករកម្ពុជា នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៦-តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ៧-តំណាងនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨-តំណាងការិយាល័យសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩-តំណាងការិយាល័យចាត់ចែងលិខិតប្រកាស នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០-តំណាងការិយាល័យបច្ចេកទេសគយនិងរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១១-តំណាងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាពនៃក្រសួងសុខាភិបាល | សមាជិក |
| ១២-តំណាងអង្គការសុខភាពពិភពលោក | សមាជិក។ |

សមាសភាពក្រុមការងារស្តីពីការយកពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់ នឹងត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ៣.-**

សមាជិកក្រុមការងារស្តីពីការយកពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានក្រុមការងារស្តីពីការយកពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់ មានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។

ប្រការ ៤-.

ក្រុមការងារស្ដីពីការយកពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់ មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ដើរតួនាទីជាក្រុមជំនាញដើម្បីសិក្សា និងរៀបចំការងារពាក់ព័ន្ធនឹងការបង្កើនថវិការដ្ឋ តាមរយៈការដំឡើងពន្ធលើផលិតផលថ្នាំជក់ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ ដែលមានផលប៉ះពាល់លើសុខភាពប្រជាជន
- រៀបចំការសិក្សានានាពាក់ព័ន្ធនឹងការតម្លើងពន្ធ ដើម្បីកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ ដែលមានផលប៉ះពាល់លើសុខភាពប្រជាជន
- ដើរតួនាទីជាក្រុមជំនាញដើម្បីសិក្សា និងរៀបចំការងារពាក់ព័ន្ធនឹងពិធីសារស្ដីពីការលុបបំបាត់ពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់ ដូចជាសិក្សាអំពីគម្លាតរវាងលក្ខខណ្ឌតម្រូវនិងកាតព្វកិច្ចក្នុងពិធីសារនិងការអនុវត្តបច្ចុប្បន្ននៅកម្ពុជា (Gap Analysis) និងផលប៉ះពាល់ចំណេញ-ខាត (Cost and Benefit Analysis) លើទិដ្ឋភាពចំណូល ច្បាប់ សេដ្ឋកិច្ច និងនយោបាយបច្ចុប្បន្ន និងអនាគតរបស់កម្ពុជា
- សម្របសម្រួលជាមួយអង្គការអន្តរជាតិ ដើម្បីចែករំលែកការអនុវត្តល្អៗ និងផ្ដល់នូវជំនួយបច្ចេកទេស
- កំណត់អាទិភាពប្រធានបទដើម្បីពិភាក្សា និងរៀបចំការប្រជុំជាទៀងរាល់ពីរខែម្ដងតាមការអញ្ជើញរបស់ប្រធានក្រុមការងារ
- ផ្ដល់អនុសាសន៍ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាក់ទិននឹងការដំឡើងពន្ធ និងពិធីសារស្ដីពីការលុបបំបាត់ការធ្វើពាណិជ្ជកម្មខុសច្បាប់លើផលិតផលថ្នាំជក់។

ប្រការ៥.-

ប្រកាសលេខ ៨៩០ សហវ. ប្រក. អពឋ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ស្ដីពីការបង្កើតក្រុមការងារស្ដីពីការយកពន្ធលើផលិតផលថ្នាំជក់ និងប្រកាសលេខ ១២០៣ សហវ.ប្រក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលក្រុមការងារស្ដីពីការយកពន្ធលើផលិតផលថ្នាំជក់ ត្រូវទុកជានិរាករណ៍។

ប្រការ៦-.

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល ÷
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ